សាកលវិទ្យាល័យជាតិគ្រប់គ្រង

National University of Management

# ឆគរបាលយុត្តិធម៌

Www.KhmerFamous.Com

# មាតិកា

## នគរបាលយុត្តិធម៌

សេចក្តីផ្តើម ................................................ ១

I. មន្ត្រីនគរបាលយុត្តិធម៌ ................................................ ២

ក.លក្ខខណ្ឌដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ................................................ ២

ក.១.ឋានន្តរសក្តិ និងមុខងាររបស់បុគ្គល ................................................ ២

ក.២.សញ្ញាប័ត្រជាន់ខ្ពស់ ................................................ ៥

ក.៣.សម្បថ ................................................ ៥

ខ.សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................................ ៦

ខ.១.មណ្ឌលរដ្ឋបាលបំពេញការងារ ................................................ ៦

ខ.២.ការពន្លាតដែនសមត្ថកិច្ច ................................................ ៦

គ.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................................ ៧

គ.១.កំណត់ហេតុ ................................................ ៨

គ.២.បញ្ជីបណ្តឹង ................................................ ៨

គ.៣. ចំណាត់ការបន្តពីការដាក់ពាក្យបណ្តឹង ................................................ ៩

ឃ.កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................................ ៩

ឃ.១.ការបំពានលើសកម្មភាពតុលាការ ................................................ ៩

ឃ.២.នីតិវិធីខាងវិន័យ ................................................ ១០

ឃ.៣.ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ................................................ ១០

ឃ.៤.ទណ្ឌកម្មខាងវិន័យ ................................................ ១០

ង.ការហាមឃាត់មិនអោយបំពេញមុខងារ ................................................ ១១

II. ភ្នាក់ងារនគរបាលយុត្តិធម៌ ................................................ ១២

ក.លក្ខខណ្ឌដើម្បីក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌ ................................................ ១២

ក.១. លក្ខខ័ណ្ឌ ................................................ ១២

ក.២. សម្បថ ................................................ ១៣

ខ.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ................................................ ១៣

គ.កំហុសរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ................................................ ១៤

គ.១. កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ ................................................ ១៤

គ.២. ទោសកម្មនៃការងារ ........................................................ ១៤
គ.៣. ទណ្ឌកម្មខាងវិន័យ ........................................................ ១៤
គ.៤. ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ........................................................ ១៤
III. មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា ........................................................ ១៥
ក.លក្ខខណ្ឌ ........................................................ ១៥
ខ.សមត្ថកិច្ចដែនដីរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ........................................................ ១៦
គ.បេសកកម្មរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ........................................................ ១៦
ឃ.កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ........................................................ ១៦
សេចក្តីសន្និដ្ឋាន ........................................................ ១៧
ឯកសារយោង ........................................................ ១៨

# នគរបាលយុត្តិធម៌

## សេចក្តីផ្តើម

ការកសាងសុំនុំរឿងព្រហ្មទណ្ឌទាមទារនូវកិច្ចផ្សេងៗ របស់នគរបាលយុត្តិធម៌ ដូចជា ការត្រួតពិនិត្យបទល្មើស និងការស្រាវជ្រាវដើម្បីអាចដាក់បន្ទុកនៃបទល្មើសទៅលើបុគ្គល ម្នាក់ ឬច្រើននាក់ ដែលត្រូវកំណត់អត្តសញ្ញាណអោយច្បាស់លាស់។

អន្តរាគមន៍របស់នគរបាលយុត្តិធម៌អាចកើតមានឡើងយ៉ាងពិតប្រាកដ ក្នុងគ្រប់ ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ សកម្មភាពរបស់នគរបាលយុត្តិធម៌ត្រូវបានចែកយ៉ាង ច្បាស់ក្នុងមាត្រា ៥៦ វាក្យខណ្ឌ ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌៈ "នគរបាលយុត្តិធម៌មាន ភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។" ហេតុដូចនេះ អន្តរាគមន៍របស់នគរបាលយុត្តិធម៌មាន សារៈសំខាន់ណាស់ ព្រោះអន្តរាគមន៍នេះនឹងធ្វើអោយកើតមានឡើយនូវសកម្មភាពបង្ក្រាប ទាំងមូល តាមរយៈការត្រួតពិនិត្យការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើស និង កសាង សំនុំរឿង។ ក្រៅពីនេះនគរបាលយុត្តិធម៌មានតួនាទីផ្តល់ពត៌មានយ៉ាងសំខាន់ដោយត្រូវជូន ដំណឹងដល់អាជ្ញាធរតុលាការដែលមានអយ្យការ និងចៅក្រមស៊ើបសួរ អំពីហេតុដែលខ្លួន បានដឹង។ ចំពោះការបង្កើតនគរបាលយុត្តិធម៌ ច្បាប់បានប្រើប្រាស់នូវបច្ចេកទេសគតិយុត្ត សាមញ្ញមួយ។ ជាទិភាពច្បាប់បានបង្កើតសមត្ថភាពដែលអាចប្រែប្រួលបានរបស់នគរបាល យុត្តិធម៌ ហើយបែងចែកសមត្ថភាពនេះរវាងភ្នាក់ងាររដ្ឋបាលផ្សេងៗដែលមានស្រាប់។ យោង តាមមាត្រា ៥៧ នគរបាលយុត្តិធម៌ត្រូវបែងចែកតាមឋានុក្រមជាបីប្រភេទ គឺ មន្ត្រីនគរបាល យុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតដែល ច្បាប់ដោយឡែកប្រគល់អំណាចអោយធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ ខ្លួន។

## I. មន្ត្រីនគរបាលយុត្តិធម៌

### ក.លក្ខខណ្ឌដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌

ដើម្បីក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌសំខាន់ៗ ដូចជា ឋានន្តរសក្តិ និងមុខងាររបស់បុគ្គល រយៈពេលដែលធ្លាប់បំរើការងារពីមុនមក សញ្ញាប័ត្រជាន់ខ្ពស់ និងសម្បថជាដើម។

#### ក.១.ឋានន្តរសក្តិ និងមុខងាររបស់បុគ្គល

យោងតាមមាត្រា ៦០ បានកំណត់:អ្នកដែលទទួលគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌មានដូចជា៖

១. មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ឡើងទៅ ដែលបានបំរើការងារយ៉ាងតិចបំផុត ២ ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

២. នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំរើការងារយ៉ាងតិចបំផុត ២ ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

៣. អ្នកដែលមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម:

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋាន កណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌនិងស្ថិតក្រោមឱវាទរបស់ នាយក

ដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានសន្តិសុខ និងនាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាននិងអនុប្រធានផ្នែកនៃ:

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

- មន្ទីរប្រឆាំងគ្រឿងញៀន

- នាយកដ្ឋាននគរបាលទេសចរណ៍

- ស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា:

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហម្មទណ្ឌកំរិតស្រាល

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

- ការិយាល័យនគរបាលសេដ្ឋកិច្ច

- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

- ការិយាល័យប្រឆាំងគ្រឿងញៀន

- ការិយាល័យប្រឆាំងភេរវកម្ម និង

- ការិយាល័យជនបទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ។

ជ. ប្រធាននិងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធ

ជាតិផ្ទុះ និង ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធ ជាតិផ្ទុះ" ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ" ។

ញ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី ១ ទី ២ និងទី៣ នៃមាត្រា ៦០ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ក.២.សញ្ញាប័ត្រជាន់ខ្ពស់**

ដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានសញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌ចំពោះមន្ត្រីនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ដែលសញ្ញាប័ត្រនេះអាចទទួលបាន បន្ទាប់ពីបានឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានរួមមាន៖ (១) វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ (២) វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ (៣) វិញ្ញាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែង នៅក្នុងក្រមសីលធម៌ដែលតាក់តែងដោយអង្គការសហប្រជាជាតិ។ ម្យ៉ាងវិញទៀត សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផង។ គណៈមេប្រយោគនៃការប្រលង ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអម តុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារ នេះ។ ចំពោះមន្ត្រីនៃនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖ ចៅក្រម ស៊ើបសួរម្នាក់ដែលតែងតាំងដោយប្រធានតុលាការកំពូល ចៅក្រមអយ្យការម្នាក់ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល តំណាង ២ របស់ពីក្រសួងមហាផ្ទៃ។ ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖ ចៅក្រមស៊ើបសួរម្នាក់ដែលតែងតាំងដោយប្រធានតុលាការកំពូល ចៅក្រមអយ្យការម្នាក់ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល តំណាង ២ រូបមកពីក្រសួងការពារជាតិ (យោងតាមមាត្រា ៦១ មាត្រា៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ក.៣. សម្បថ**

ជាលក្ខខណ្ឌមួយដែលសំខាន់ផងដែរ មុនបំពេញមុខងារ ចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន។ សម្បថនេះត្រូវធ្វើឡើងនៅមុខសាលាឧទ្ធរណ៍។ ម្យ៉ាងវិញទៀតសម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតទេ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។

រូបមន្តនៃសម្បថកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (យោងតាមមាត្រា ៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ខ.សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌**

**ខ.១.មណ្ឌលរដ្ឋបាលបំពេញការងារ**

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងអោយទៅបំរើការងារ។ ជាក់ស្តែង នៅទីក្រុងភ្នំពេញ មន្ត្រីនគរយុត្តិធម៌ មានសមត្ថកិច្ចលើវិសាលភាពទីក្រុងភ្នំពេញទាំងមូល ដោយមិនគិតពីអង្គភាពចាត់តាំងរបស់ខ្លួន។

**ខ.២.ការពន្លាតដែនសមត្ថកិច្ច**

សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌អាចពង្រីកលើវិសាលភាពនៃដែន ដីប្រទេសទាំងមូលដោយ ព្រះរាជអាជ្ញា ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ឬក្នុង ករណីបន្ទាន់។ ចៅក្រមស៊ើបសួរក៏អាចពង្រីកសមត្ថកិច្ចដែនដី របស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលចេញដីកាចាត់អោយស៊ើបសួរជំនួសដោយមានបញ្ជាក់ពីលក្ខណៈបន្ទាន់។ អន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌នៅក្រៅដែនសមត្ថកិច្ច ត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងតំបន់នោះ។ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ក៏ត្រូវទទួលបានដំណឹងអំពីអន្តរាគមន៍នេះផងដែរ ដោយចៅក្រមដែលបានពង្រីកសមត្ថកិច្ចខាងដែនដី ក៏ត្រូវទទួលបានដំណឹងអំពីអន្តរាគមន៍ ក្រៅដែនសមត្ថកិច្ចរបស់ខ្លួន។ គ្រប់អន្តរាគមន៍ក្រៅដែនសមត្ថកិច្ចដែលពុំទទួលបានការអនុញ្ញាតពីចៅក្រមពុំមានសុពលភាពទេ ហើយការស៊ើបអង្កេតត្រូវចាត់ទុកជាមោឃៈ។ ជាក្របខ័ណ្ឌនៃមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួនទទួលបញ្ជា ឬសុំ បញ្ជាតែពី អាជ្ញាធរតុលាការ។ នៅក្នុងមាត្រា ៦៩ បានចែងថា: វិធាននៃសមត្ថកិច្ចខាង ដែនដីដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗ (ដែលពាក់ព័ន្ធ) មានលក្ខណៈដាច់ខាត់ មានន័យថាត្រូវតែបំពេញអោយ

គ្រប់វិធាននីមួយៗ។ បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ។

**គ.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌**

បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌គឺជាមុខងារដែលត្រូវបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្មសំខាន់ៗដូចតទៅៈ

- ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារ បណ្តឹងតវ៉ា ពីសាធារណជន
- ពិនិត្យបទល្មើសទាំងឡាយរួមមាន បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ
- ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋម
- កាលណាការការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកាចាត់អោយស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរនៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា ១៧៣។
- ចាត់ចែងប្រមូលភស្តុតាង ទាំងតាមរយៈការចាប់ផ្តើមស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ (ក្នុងករណីបទល្មើសជាក់ស្តែង មានន័យថាករណីដែលអ្នកប្រព្រឹត្តបទល្មើសត្រូវបានចាប់នៅនឹងកន្លែង) ឬក្រោមអំណាចដឹកនាំរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេត(ក្នុងករណីបទល្មើសមិនជាក់ស្តែង)។
- ធ្វើកំណត់ហេតុ (ឬរបាយការណ៍នគរបាលៈ លិខិតលាយលក្ខណ៍អក្សររៀបរាប់អំពីអង្គហេតុនៃរឿងក្តី។)
- ក្នុងករណីបទល្មើសជាក់ស្តែង អាចសំរេចឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេល ៤៨ ម៉ោង យ៉ាងយូរ ប្រសិនបើមានការសង្ស័យសមហេតុផល សំរាប់ធ្វើជាមូលដ្ឋានចោទប្រកាន់បាន។
- សុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេលមិនលើសពី ២៤ ម៉ោង កាលណាលក្ខខណ្ឌទាំង ៥ ត្រូវបានបំពេញដែលមានដូចជាៈ (១)ករណីបទឧក្រិដ្ឋធ្ងន់ធ្ងរ (២) មានតម្រុយចង្អុលបង្ហាញច្បាស់លាស់ថាបានប្រព្រឹត្តបទល្មើស (៣) ជាវិធានការចាំ បាច់ដើម្បី

អោយការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ (៤) ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល និង (៥) មានចំណារយល់ព្រមពីព្រះរាជអាជ្ញា។

**គ.១. កំណត់ហេតុ**

យោងតាមមាត្រា ៧២ បានចែងថា: គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ ត្រូវអោយធ្វើកំណត់ហេតុ។ កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថាខ្លួននឹងបកប្រែភាសាអោយបានត្រឹមត្រូវតាមសេចក្តីរាយការណ៍។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តការបានឡើយ។ កំណត់ហេតុស្តីអំពីការដាក់ពាក្យប្តឹងត្រូវមានចុះសេចក្តីដូចតទៅ: (១) ឈ្មោះនិងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ (២) អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ (៣) កាលបរិច្ឆេទ។ ម្យ៉ាងវិញទៀត ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរ បាលយុត្តិធម៌ និងដោយអ្នកប្តឹង។ ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង នៅរឹមទំព័រ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំលេងខ្លាំងៗ។

**គ.២. បញ្ជីបណ្តឹង**

យោងតាមមាត្រា ៧២ បានចែង: នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីមួយ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះបញ្ជីនូវនិទ្ទេសដូចតទៅ៖ (១) អត្តសញ្ញាណរបស់អ្នកប្តឹង (២) កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង (៣)

ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យ ប្តឹង (៤) ប្រភេទនៃអំពើដែលប្តឹង (៥) ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត។ បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ។

**គ.៣.ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង**

ជាក់ស្តែងនៅក្នុងមាត្រា ៧៤ ចែងថា: មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះ ត្រូវតែចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ។ ម្យ៉ាងវិញទៀត មន្ត្រីនគរបាលយុត្តិធម៌ មុននឹងធ្វើការស៊ើបអង្កេត អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ កាលណាទទួលពាក្យប្តឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល។

**ឃ.កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌**

**ឃ.១.ការបំពានលើសកម្មភាពតុលាការ**

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្តឹងក៏ដោយ។មន្ត្រីនគរបាលយុត្តិធម៌ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬក៏លាក់បំបាំងដល់អាជ្ញាធរតុលាការអំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថាមន្ត្រីនគរ បាលយុត្តិធម៌នោះបានប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌពាក់ ព័ន្ធនឹងជំពូកស្តីពីការស្រាវជ្រាវរកភស្តុតាង (យោងតាមមាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ឃ.២.នីតិវិធីខាងវិន័យ**

បើយោងទៅតាមមាត្រា ៦៤ បានកំណត់ថា: ព្រះរាជា ឬចៅក្រមស៊ើបសួរ ជាអ្នកដឹកនាំមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែរាយការណ៍ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នូវរាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួន។ ក្នុងករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ អគ្គព្រះ រាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យ នេះ។

**ឃ.៣.ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ**

រាល់បទល្មើសព្រហ្មទណ្ឌទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌គឺត្រូវអនុវត្តបណ្តឹងអាជ្ញាធម្មតាដូចជនដទៃដែរ ហើយប្រសិនបើមាបទល្មើសណាមួយត្រូវបានប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧសគ្គដល់ការធ្វើបណ្តឹងអាជ្ញានៃបទល្មើសឡើយ។

**ឃ.៤.ទណ្ឌកម្មខាងវិន័យ**

ជាទូទៅ ប្រសិនបើមាបទល្មើសណាមួយត្រូវបានប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧសគ្គដល់ការធ្វើបណ្តឹងអាជ្ញានៃបទល្មើសឡើយ។ បើកាលណាមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់ តុលាការកំពូលទៅអោយយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី។

**ខ.ការហាមឃាត់មិនអោយបំពេញមុខងារ**

ការហាមឃាត់មិនអោយបំពេញមុខងារជាទណ្ឌកម្មដែលត្រូវបានដាក់ទៅលើមន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលខ្លួនបានប្រព្រឹត្តកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួន។ តាមមាត្រា ៦៦ នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិប្រកាស ចេញវិធានការដូចតទៅ៖

- ហាមឃាត់មិនអោយបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើនបំផុត។
- ហាមឃាត់មិនអោយបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ មានន័យថាជារៀងរហូត។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវកោះហៅមន្ត្រីនគរបាលយុត្តិធម៌ និង កត់ត្រាទុកនូវសេចក្តីសង្កេតរបស់មន្ត្រីនោះ មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានកោះហៅអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់តាមការជ្រើសរើសរបស់ខ្លួន។ សេចក្តីសម្រេចពីការហាមឃាត់ខាងលើនេះ ត្រូវតែបញ្ជាក់សំអាងហេតុ ពោលគឺអំពីមូលហេតុដែលនាំអោយមានការហាមឃាត់នេះ។ សេចក្តីសម្រេចអំពីការហាមឃាត់ត្រូវផ្តល់ដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ។ ម្យ៉ាងវិញទៀត សេចក្តីសម្រេចនេះ អាចប្តឹងតវ៉ាបានទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលអាចប្រកាសបដិសេធចោលនូវការសម្រេចហាមឃាត់ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុ ក្នុងអំឡុងពេល ១៥ ថ្ងៃគិតពីថ្ងៃទទួលដំណឹងអំពី សេចក្តីសម្រេចហាមឃាត់។ មួយវិញទៀត ក្រសួងសាមីនៃមន្ត្រី

នគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះអាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើនេះ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ ខែ គិតពីថ្ងៃទទួលពាក្យប្តឹង។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ។ គួរកត់សំគាល់ផងដែរ នៅក្នុងអំឡុងពេលដែលអាចប្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ាមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់។ ត្រូវចងចាំថា កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញ ដោយបំពានសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះត្រូវចាត់ទុកជាមោឃៈ។

## II. ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធិស្ថិតនៅក្នុងផ្នែកមួយនៃនគរបាលយុត្តិធម៌បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់លក្ខខណ្ឌពិសេសមួយចំនួន ដើម្បីទទួលបានជាភ្នាក់ងារនគរបាលយុត្តិធម៌ដែលមានបរិយាយដូចខាងក្រោមនេះ៖

### ក.លក្ខខណ្ឌដើម្បីក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌

#### ក.១. លក្ខខ័ណ្ឌ

ភ្នាក់ងារនគរបាលយុត្តិធម៌ សំដៅលើ៖

ក. នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តធម៌

ខ. ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ

គ.នាយទាហាននៃកងរាអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តធម៌
ឃ. យោធនផ្សេងទៀតនៃកងរាជអាវុធហត្ថ។

**ក.២. សម្បថ**

ភ្នាក់ងារនគរបាលយុត្តិធម៌នីមួយៗ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងថានឹងបំពេញ មុខងាររបស់ខ្លួនដោយស្មោះត្រង់។ ប្រសិនបើភ្នាក់ងារនគរបាលយុត្តិធម៌នីមួយៗនោះបានទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលក្រោយទៀត នោះគាត់ពុំចាំបាច់ធ្វើសម្បថជាថ្មីម្តងទៀតឡើយ។

**ខ.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើស និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន។ ភ្នាក់ងារនគរបាលយុត្តិធម៌ ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ដោយធ្វើការប្រមូលពត៌មាន ហើយធ្វើជារបាយការណ៍ដែលមានតម្លៃត្រឹមតែជាពត៌មានធម្មតាជូនទៅមន្ត្រីនគរបាលយុត្តិធម៌។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ភ្នាក់ងារនគរបាលយុត្តិធម៌ជាអង្គនៃការគ្រប់គ្រងនិងការអនុវត្តន៍។

យោងតាមមាត្រា ៧៨ បានចែងថា:ភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្មដូចជា៖ (១) ពិនិត្យបទល្មើសជាអាទិ៍ បទលហុ។ (២) ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ។ ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍។ របាយការណ៍នេះ មានតំលៃត្រឹមតែព័ត៌មានធម្មតា។ ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះត្រូវចាត់ទុកជាមោឃៈ។

## គ.កំហុសរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

### គ.១. កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរជាអ្នកអោយដំណឹងពីកំហុសរបស់ភ្នាក់ងារនគរបាល យុត្តធម៌ក្នុងពេលបំពេញមុខងាររបស់ខ្លួនជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទរណ៍។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។

### គ.២. មោឃកម្មនៃការងារ

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយណាដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបាន បំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ។

### គ.៣. ទណ្ឌកម្មខាងវិន័យ

កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន តុលាការកំពូលអាចផ្ទេរអំណាចអោយទៅយុត្តាធិការផ្សេងចាត់ការវិញបានដើម្បីប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ។ ពាក្យសុំដកសិទ្ធិរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ពីមុខងារត្រូវធ្វើ ឡើងដោយព្រះរាជអាជ្ញា។

### គ.៤. ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌ ទណ្ឌកម្ម ខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧបសគ្គដល់ការ ធ្វើបណ្តឹងអាជ្ញាទេ។

## III. មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា

ក្នុងចំណោមបេសកកម្មដែលទទួលបាន ភ្នាក់ងារសាធារណៈជាច្រើនមានបេសកកម្មបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើល្មើសទៅលើច្បាប់ដែលគ្រប់គ្រងវិស័យរបស់ខ្លួន ដូចជា ពិនិត្យកត់ត្រាការប្រព្រឹត្តទាំងនេះជាដើម។ ភ្នាក់ងារនេះក៏ស្ថិតនៅក្រោមអំណាចរបស់ ព្រះរាជអាជ្ញានៅពេលដែលខ្លួនបំពេញតួនាទីជានគរបាលយុត្តិធម៌។ ភ្នាក់ងារទាំងនេះស្បថ ថានឹងបំពេញតួនាទីដោយស្មោះត្រង់នៅចំពោះមុខសាលាដំបូង។ ជាចុងក្រោយ ច្បាប់ដោយឡែកមួយចំនួនអាចផ្តល់នីតិសម្បទា នៅក្នុងរយៈពេលកំរិតមួយ និងក្នុងសមត្ថកិច្ចដោយឡែកមួយចំនួនដល់មន្ត្រីរាជការមួយចំនួនអោយក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលយុត្តិធម៌។ ក្រមនីតិវិធីព្រហ្មទណ្ឌ ទទួលស្គាល់លទ្ធភាពនេះជាទូទៅដូចមាន ចែងនៅក្នុងមាត្រា ១ ដែលបញ្ញត្តថា: "បទបទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះ រឿងព្រហ្មទណ្ឌកាលណាពុំមាន វិធានដោយឡែកចែងដោយច្បាប់ពិសេស ទេនោះ"។

### ក.លក្ខខណ្ឌ

យោងតាមមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តថា: "មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចអោយពិនិត្យ បទល្មើសត្រូវដាក់អោយស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។

របៀបបទនិង នីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង។ រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

**ខ.សមត្ថកិច្ចដែនដីរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ**

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈបំពេញមុខងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលច្បាប់កំណត់តែប៉ុណ្ណោះ។

**គ.បេសកកម្មរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ**

ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និង ភ្នាក់ងារទាំងនោះធ្វើរបាយការណ៍។ របាយការណ៍នេះមានតំលៃត្រឹមតែពត៌មានធម្មតាប៉ុណ្ណោះ។

**ឃ.កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ**

នៅក្នុងមាត្រា ៨២ ក៏បានបញ្ញត្តផងដែរថា: "រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែអោយដំណឹងដោយ ព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។"

# សេចក្តីសន្និដ្ឋាន

# ឯកសារយោង

☞ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

☞ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

☞ មេរៀន និងស្លាយនីតិវិធីព្រហ្មទណ្ឌកម្ពុជារៀបរៀងដោយសាស្ត្រាចារ្យ ឯក សេងហួត

☞ គេហទំព័រ:

- http://1.bp.blogspot.com/_ljcW16eVHo/TP7F7CdE2OI/AAAAAAAAALs/FHMUrYE44YY/s1600/FairTrialHandbookJudicialPoliceOfficersWhatTheyDoKHM.jpg
- www.cambodialaw.com